### សម្រេច

**មាត្រា ១ .**_ ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ២.០០០ លានរៀល (ពីរពាន់លានរៀល) ពីជំពូក ៥០ ( ចំណាយផ្សេងៗ ) ចំនួន ៧៨០ លានរៀល ( ប្រាំពីររយប៉ែតសិបលានរៀល ) និង ពីជំពូក ៥១ ( ចំណាយឥតគ្រោងទុក ) ចំនួន ១.២២០ លានរៀល ( មួយពាន់ពីររយម្ភៃលានរៀល ) នៃខ្ទង់ចំណាយមិនទាន់បែងចែកមកជំពូក ១១ ( ចំណាយដំណើរការរដ្ឋបាល សំភារះ និង ការជួសជុលតូច ) របស់ក្រសួងអប់រំ យុវជន និង កីឡា ផ្នែក អប់រំ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៩ ។

**មាត្រា ២ .**_ ឥណទានថវិកាក្នុងមាត្រា ១ ខាងលើត្រូវបានអនុញ្ញាតអោយប្រើប្រាស់ សំរាប់បោះពុម្ពសៀវភៅសិក្សាចំណេះទូទៅថ្នាក់ទី ១០ សំរាប់សិស្ស និងគ្រូ ប្រចាំឆ្នាំ ១៩៩៩ ។

**មាត្រា ៣ .**_ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី០៥ ខែឧសភា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ៨០ អនក្រ.បក
## ស្តីពីការបង្កើតគណៈកម្មាធិការជាតិរៀបចំទិវាមនុស្សចាស់អន្តរជាតិ និង ជួយជនចាស់ជរា

***

### រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ និង អតិតយុទ្ធជន
- បានឃើញអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ១៩៩៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិរៀបចំទិវាមនុស្សចាស់អន្តរជាតិ និង ជួយជនចាស់ជរា
- បានការយល់ព្រមពីគណៈរដ្ឋមន្ត្រីនាសម័យប្រជុំពេញអង្គថ្ងៃទី០២ ខែតុលា ឆ្នាំ១៩៩៨

LAW-SOCIETY ASIA

ើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា

- យោងសេចក្តីសំរេចរបស់គណៈកម្មាធិការអភិវឌ្ឍន៍សង្គម នៃអង្គការសហប្រជាជាតិ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ១៩៩៧

**សំរេច**

**មាត្រា ១ .**_ បង្កើតគណៈកម្មាធិការជាតិរៀបចំទិវាមនុស្សចាស់អន្តរជាតិ និង ជួយជនចាស់ជរា ដែលមានសមាសភាពដូចតទៅ ៖

១-សម្តេច នាយករដ្ឋមន្ត្រី ជាប្រធានកិត្តិយស

២-រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា ជាប្រធាន

៣-រដ្ឋលេខាធិការក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា ជាអនុប្រធាន

៤-អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី និង អតីតយុទ្ធជន ជាអនុប្រធាន

៥-អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល ជាអនុប្រធាន

៦-តំណាងក្រសួងមហាផ្ទៃ ជាសមាជិក

៧-តំណាងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ជាសមាជិក

៨-តំណាងក្រសួងធម្មការ និងសាសនា ជាសមាជិក

៩-តំណាងក្រសួងអភិវឌ្ឍន៍ជនបទ ជាសមាជិក

១០-តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសមាជិក

១១-តំណាងក្រសួងព័ត៌មាន ជាសមាជិក

១២-តំណាងគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ និងអន្តរជាតិ ជាសមាជិក

១៣-តំណាងគណៈកម្មការសមាគមជាតិកាកបាទក្រហមកម្ពុជា ជាសមាជិក

**មាត្រា ២ .**_ គណៈកម្មាធិការនេះអាចមានទីប្រឹក្សាបច្ចេកទេសស្ម័គ្រចិត្តតាមការចាំបាច់ ដោយស្នើពីសមាគមមនុស្សចាស់នានានៅកម្ពុជា អង្គការមិនមែនរដ្ឋាភិបាលក្នុង និងក្រៅប្រទេស និងអង្គការអន្តរជាតិ ។

**មាត្រា ៣ .**_ គណៈកម្មាធិការនេះមានភារកិច្ចដូចតទៅ ៖

១-រៀបចំគោលនយោបាយជាតិ ដើម្បីលើកស្ទួយសុខុមាលភាពរបស់មនុស្សចាស់ ពិសេសជនចាស់ជរាអោយប្រសើរឡើង ។

២-រៀបចំទិវាមនុស្សចាស់អន្តរជាតិ ជារៀងរាល់ឆ្នាំដោយកំណត់យកថ្ងៃទី០១ ខែតុលា ។

៣-សហការសម្របសម្រួលជាមួយស្ថាប័នជាតិ អង្គការជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាលក្នុងនិងក្រៅប្រទេស និងសប្បុរសជននានាដើម្បីចូលរួមឧបត្ថម្ភគាំទ្រដល់ជនចាស់ជរានៅកម្ពុជា ។

៥-លើកតំកើងថវិកាជាតិ ដែលស្ថិតក្នុងបន្ទុកផែនការថវិកាចំណាយ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទាសំរាប់រៀបចំទិវាមនុស្សចាស់អន្តរជាតិជារៀងរាល់ឆ្នាំនិង សំរាប់បំពេញកម្មវិធីសេវាកម្មផ្សេងៗ ដល់មនុស្សចាស់ ។

៥-បង្កើតអនុគណៈកម្មាធិការរៀបចំទិវាមនុស្សចាស់អន្តរជាតិ និងជួយជនចាស់ជរាតាមខេត្ត-ក្រុង តាមការចាំបាច់ ។

**មាត្រា ៤ .-** សមាជិកនៃគណៈកម្មាធិការនេះ ត្រូវចូលរួមប្រជុំតាមសេចក្តីអញ្ជើញរបស់ប្រធាន ។

**មាត្រា ៥ .-** គណៈកម្មាធិការជាតិរៀបចំទិវាមនុស្សចាស់អន្តរជាតិ និងជួយជនចាស់ជរាត្រូវកំណត់តួនាទីភារកិច្ច នៃតំណាងក្រសួង ស្ថាប័ន ដូចមានចែងក្នុងមាត្រា ១ នៃអនុក្រឹត្យនេះអាចបង្កើតលេខាធិការដ្ឋាន អចិន្ត្រៃយ៍មួយ ប្រចាំនៅក្រសួងសង្គមកិច្ច ការងារបណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទាដោយ ប្រើក្របខ័ណ្ឌមានស្រាប់ ដើម្បីជំនួយការក្នុងកិច្ចសហការសម្របសម្រួលដោះស្រាយរាល់ការងារ ដែលពាក់ព័ន្ធ បញ្ហាជនចាស់ជរាកម្ពុជា និងដំណើរការរៀបចំទិវាមនុស្សចាស់អន្តរជាតិ ។ តួនាទី និងភារកិច្ចរបស់លេខាធិការដ្ឋានអចិន្ត្រៃយ៍ត្រូវកំណត់ដោយគណៈកម្មាធិការជាតិរៀបចំទិវាមនុស្ស ចាស់អន្តរជាតិ និងជួយជនចាស់ជរា ។ គណៈកម្មាធិការជាតិនេះត្រូវប្រើត្រាក្រសួងសង្គមកិច្ច ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ដើម្បីដំណើរការ ។

**មាត្រា ៦ .-** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៧ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងពាក់ព័ន្ធ និងគ្រប់អង្គការជាតិដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី០៧ ខែឧសភា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

## អនុក្រឹត្យលេខ ៤១ អនក្រ.បក

## ស្តីពីការបង្កើតក្រុមប្រឹក្សាដោះស្រាយគេចកំលាំងប្រដាប់អាវុធ

***

### រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា